ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំណត់ហេតុ
កិច្ចប្រជុំលើកទី៦របស់ក្រុមការងាររេដបូកកម្ពុជា

ឆ្នាំពីរពាន់ដប់បួន ខែធ្នូ ថ្ងៃទី៣០ វេលាម៉ោងប្រាំបួន នៅសណ្ឋាគារ រ៉ក់រ៉ូយ៉ាល់ ក្រុងកែប ខេត្តកែប មានបើកកិច្ចប្រជុំលើកទី៦ក្រុមការងាររេដបូកកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ និងជាប្រធានក្រុមការងាររេដបូកកម្ពុជា។ កិច្ចប្រជុំនេះរៀបចំឡើងដោយលេខាធិការដ្ឋានរេដបូក ដោយមានសមាសភាពចូលរួមសរុបចំនួន ៣៥នាក់ រួមមាន៖ សមាជិកក្រុមការងាររេដបូក ០៩នាក់ មន្ត្រីបច្ចេកទេស ១៣នាក់ និងអ្នករៀបចំមកពីលេខាធិការដ្ឋានរេដបូក ១១នាក់ និងអ្នកចូលរួមគាំទ្រចំនួន ០២នាក់ (ឧបសម្ព័ន្ធ០១៖ បញ្ជីរាយនាមអ្នកចូលរួម)។

១-មតិចាប់ផ្តើមបើកអង្គប្រជុំ

ឯកឧត្តមបណ្ឌិត ជា សំអាង ស្វាគមន៍សមាជិក សមាជិកាដែលបានចូលរួម និងស្នើសុំឲ្យសមាជិក សមាជិកាក្រុមការងាររេដបូកពិនិត្យ ផ្តល់យោបល់ទៅលើរបៀបវារៈនៃកិច្ចប្រជុំ(ឧបសម្ព័ន្ធ០២៖ របៀបវារៈកិច្ចប្រជុំ)។

ឯកឧត្តម បានជម្រាបជូនពីគោលបំណងនៃកិច្ចប្រជុំ និងបានសង្ខេបពីវឌ្ឍនភាព និងលទ្ធផលការងារដែលក្រុមបច្ចេកទេស និងលេខាធិការដ្ឋានបានអនុវត្តនាពេលកន្លងមកជូនសមាជិកក្រុមការងាររេដបូកផងដែរ (ឧបសម្ព័ន្ធ០៣៖ មតិស្វាគមន៍ក្នុងពិធីបើកកិច្ចប្រជុំ)។

២-បទបង្ហាញ និងកិច្ចពិភាក្សា

២.១ ស្ថានភាពការងារបច្ចុប្បន្នរបស់ក្រុមការងាររេដបូក

២.១.១ ផែនការការងារឆ្នាំ២០១៥

លោកបណ្ឌិត ឃនសារ៉ែត ប្រធានលេខាធិការដ្ឋានរេដបូក បានជម្រាបជូនអង្គប្រជុំពីការបន្តគាំទ្រសកម្មភាព នឹងពង្រឹងសមត្ថភាព ក្រុមការងាររេដបូក លេខាធិការដ្ឋាន ក្រុមបច្ចេកទេស និងក្រុមប្រឹក្សាយោបល់ ក៏ដូចជាការគាំទ្រដល់សកម្មភាពរៀបចំគោលនយោបាយ យុទ្ធសាស្ត្ររេដបូកជាតិ និងសមាសធាតុការងារសំខាន់ៗ សម្រាប់គាំទ្រដល់ការអនុវត្តរេដបូកនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ឧបសម្ព័ន្ធ០៤៖ បទបង្ហាញស្តីពីផែនការការងារឆ្នាំ២០១៥)។

ការពិភាក្សា

ឯកឧត្តមបណ្ឌិត ជា សំអាង៖ សកម្មភាពដែលបានបង្ហាញទាំងនេះ ជាសកម្មភាពដែលត្រូវធ្វើបន្តលើកិច្ចការងាររេដបូកដែលយើងបានអនុវត្តកន្លងមក។ HJ

ឯកឧត្តម ជាម ប៉េអាះ សេចក្តីរាយការណ៍ពីការកសាងសមត្ថភាពនៅថ្នាក់ក្រោមជាតិ បានផ្តោតសំខាន់លើស្ថាប័នអនុវត្តទាំងបីគឺ រដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិនិងរដ្ឋបាលជលផល។ ចាប់ពីឆ្នាំ២០១៥ទៅយើងត្រូវគិតគូរការកសាងសមត្ថភាពដោយរួមបញ្ចូលរដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅសាលាខេត្ត ក្រុង ស្រុក មានទីចាត់ការអន្តរវិស័យដែលជួយគណបញ្ជាការឯកភាពខេត្តលើកិច្ចការងារវិស័យ ដើម្បីជួយអន្តរាគមន៍ទាន់ពេលវេលា ជាពិសេសការការពារ និងអភិរក្សធនធានធម្មជាតិ។ ប្រសិនបើទីចាត់ការនេះយល់ពីកិច្ចការងាររដេបូកយើងនឹងអាចជួយបានច្រើន។ ម្យ៉ាងទៀតនៅក្នុងក្របខណ្ឌនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ដូច្នេះការងារទាំងអស់ត្រូវប្រមូលផ្តុំនៅក្រោមក្រុមប្រឹក្សា ប្រសិនបើការផ្តល់សេវារបស់រដ្ឋជូនប្រជាពលរដ្ឋមិនស្ថិតក្រោមក្របខណ្ឌក្រុមប្រឹក្សានេះទេ អាចនឹងមានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកនយោបាយ ជាពិសេសការគាំទ្រ និងការជ្រើសរើសក្រុមប្រឹក្សា។

ឯកឧត្តមបណ្ឌិត ជា សំអាង៖ ឯកភាពនិងមតិលើកឡើងរបស់ឯកឧត្តម ជាម ប៉េអា ដោយហេតុថារដ្ឋបាលថ្នាក់ក្រោមជាតិ ជាអ្នកចូលរួមអនុវត្តសកម្មភាព ប្រសិនបើខ្វះការចូលរួម ការអនុវត្តសកម្មភាពរដេបូកមិនអាចទទួលបានជោគជ័យឡើយ។ នេះជាការចាំបាច់ដែលត្រូវរួមបញ្ចូលរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបង្កើនចំណេះដឹងនៅក្នុងឆ្នាំ២០១៥នេះ។

លោក ញ៉ែម សុវណ្ណា៖ យើងមានថវិកាប្រមាណជាង៦សែន សម្រាប់ការកសាងសមត្ថភាព។ កន្លងមកការកសាងសមត្ថភាពបានធ្វើទៅដល់សហគមន៍ ពិតមែនថាយើងមិនបានរួមបញ្ចូលរដ្ឋបាលថ្នាក់ក្រោមជាតិប៉ុន្តែនៅពេលយើងពង្រឹងសមត្ថភាពសហគមន៍ យើងបានអនុវត្តតាមរយៈក្រុមប្រឹក្សាឃុំដើម្បីជួយលើបញ្ហានេះ។ ការផ្តល់យោបល់ខាងលើនេះពិតជាមានសារសំខាន់ ដូច្នេះប្រសិនបើអង្គប្រជុំគាំទ្រ យើងនឹងដាក់ថវិកាដើម្បីរួមបញ្ចូលរដ្ឋបាលមូលដ្ឋានក្នុងការកសាងសមត្ថភាពរដេបូក។

លោក គឹម ណុង៖ យើងបានដឹងហើយថា យើងកំពុងរៀបចំគោលនយោបាយរដេបូកផង និងកសាងសមត្ថភាពផង។ បច្ចុប្បន្នអគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ កំពុងបញ្ជ្រាបការងាររដេបូកទៅតាមខ្សែបណ្តោយនៅថ្នាក់ក្រោមជាតិដូចជាប្រធានមន្ទីរបរិស្ថាន និងនាយកឧទ្យាន ដែលជាសមាជិកគណបញ្ជាការឯកភាពខេត្តដែរ ជាមួយគ្នានេះយើងក៏បានពិចារណាពីការរួមបញ្ចូលរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ នៅតាមស្ថាប័នជំនាញកញ្ចប់ថវិកាមានកំណត់ ដែលប្រើសម្រាប់បង្កើនការយល់ដឹងផង និងអនុវត្តនៅថ្នាក់ក្រោមជាតិផង។

លោកបណ្ឌិត ដោក ដូម៉ា៖ ជាបទពិសោធន៍ក្នុងការបញ្ជ្រាបការបណ្តុះបណ្តាលស្តីពីប្រព័ន្ធធានាសុវត្ថិភាពគម្រោងឃុំសង្កាត់ គឺយើងគ្រាន់តែដាក់បញ្ចូលប្រធានបទនេះជាផ្នែកមួយនៅក្នុងកម្មវិធីបណ្តុះបណ្តាលនៃការ កសាងសមត្ថភាពនៅថ្នាក់ក្រោមជាតិប៉ុណ្ណោះ យើងមិនចុះអនុវត្តដោយខ្លួនឯងឡើយ។

ឯកឧត្តម ជាម ប៉េអាះ រាជរដ្ឋាភិបាលបានសម្រេចក្នុងការបង្កើតឲ្យមានមជ្ឈមណ្ឌលបណ្តុះបណ្តាលនៅថ្នាក់ខេត្តដោយមានអភិបាលរងម្នាក់ដឹកនាំ។ មជ្ឈមណ្ឌលនេះនឹងផ្តល់ការបណ្តុះបណ្តាលទៅតាមសេចក្តីត្រូវការដែលឆ្លើយតបនឹងកម្មវិធីអភិវឌ្ឍជាក់លាក់នៅក្នុងខេត្ត ។ ឯកឧត្តមនឹងជួយសម្របសម្រួល ប្រសិនបើរដេបូកយើងអនុវត្តការពង្រឹងសមត្ថភាពដោយរួមសហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលនៅថ្នាក់ខេត្ត។

<u>សេចក្តីសម្រេច</u>

- លេខាធិការដ្ឋានត្រូវរៀបចំផែនការកសាងសមត្ថភាពដោយសហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលនៅថ្នាក់ខេត្ត HY

- លេខាធិការដ្ឋានរៀបចំកម្មវិធី វិធីសាស្ត្រ និងឯកសាររេដបូក និងចុះអនុវត្តការបណ្តុះបណ្តាលដោយមានមន្ត្រីបច្ចេកទេសទាំងបួននាក់មកពីក្រសួងមហាផ្ទៃ ជួយសម្របសម្រួលជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលនៅថ្នាក់ខេត្ត ដើម្បីអនុវត្តកម្មវិធីបណ្តុះបណ្តាលរេដបូក ។

<u>២.១.២ ការបង្កើតយុទ្ធសាស្ត្ររេដបូកជាតិ</u>

លោក ងួន ភក្តី ទីប្រឹក្សាជាតិ បានបញ្ជាក់ថា យុទ្ធសាស្ត្ររេដបូកជាតិ ជាលទ្ធផលដ៏សំខាន់នៃដំណាក់កាលត្រៀមលក្ខណៈអនុវត្តរេដបូក និងជាតម្រូវការដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ 1/CP.16. កថាខណ្ឌទី ៧១ និងសេចក្តីសម្រេចលេខ 2/CP.17. កថាខណ្ឌទី ៦៨ របស់ UNFCCC។ លោក ងួន ភក្តី ក៏បានបង្ហាញពីដំណាក់កាលជាបន្តបន្ទាប់ ក្រុមបច្ចេកទេស មូលដ្ឋានគតិយុត្តិ និងឯកសារយោងនានា សម្រាប់គាំទ្រដល់ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ។ អត្ថបទសំខាន់ដែលមាននៅក្នុងសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិក៏បានដកស្រង់ និងបង្ហាញជូនកិច្ចប្រជុំផងដែរ <u>ឧបសម្ព័ន្ធ០៥៖ បទបង្ហាញស្តីពីការបង្កើតយុទ្ធសាស្ត្ររេដបូកជាតិ)</u>។

<u>ការពិភាក្សា</u>

ឯកឧត្តមបណ្ឌិត ជា សំអាង ៖ យើងមានពេលវេលាខ្លីដើម្បីរៀបចំយុទ្ធសាស្ត្ររេដបូកជាតិឲ្យបានទាន់ពេលវេលាកំណត់ ដូច្នេះសូមសមាជិកក្រុមការងាររេដបូកជាតិជួយផ្តល់យោបល់។ ឯកឧត្តមជូនព័ត៌មានថា វៀតណាមបានរៀបចំរួចរាល់យុទ្ធសាស្ត្ររេដបូកជាតិរបស់គេ។ ផ្អែកលើយុទ្ធសាស្ត្រនេះ វៀតណាមបានទទួលថវិកាជំនួយពីប្រទេសណារវេស ជំហ៊ានទី១ ចំនួន៣០លានដុល្លា សម្រាប់អនុវត្តយុទ្ធសាស្ត្រនេះនៅលើទីវាល ដើម្បីសម្រេចបានការគ្រប់គ្រងធនធានព្រៃឈើដោយជោគជ័យ។

លោក អ៊ុយ កាម៉ាល ៖ សង្កេតឃើញថាការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ មិនបានបញ្ជាក់ពីប្រើប្រាស់ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុមកធ្វើជាឯកសារយោង។ ចំណុចមួយទៀត យុទ្ធសាស្ត្ររេដបូកជាតិមិនបានរំលេចពីស្ថានភាព និងកាលៈទេសៈពិសេសរបស់កម្ពុជា ចំណុចនេះសំខាន់ដែលអាចជួយឲ្យគេបានយល់ពីស្ថានភាពពិសេសរបស់កម្ពុជា និងអាចធ្វើអន្តរាគមន៍ដើម្បីឲ្យយើងអាចអភិវឌ្ឍទាន់ស្ថានភាពពិភពលោក។

ឯកឧត្តមបណ្ឌិត ជា សំអាង ៖ ស្នើឲ្យសិក្សាស្រាវជ្រាវសម្រាប់ជាឯកសារយោងបន្ថែមទៀត ជាពិសេសឯកសារយុទ្ធសាស្ត្រជាតិដែលបានធ្វើបច្ចុប្បន្នភាពថ្មីៗកន្លងមកនេះ។

លោកអ៊ុកវិបុល ៖ សូមកោតសរសើរទីប្រឹក្សាជាតិ ដែលមានសមត្ថភាពរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ។ លោកបញ្ជាក់ថាបន្ទាប់ពីបានសម្រេចលុបចោលឡូត៍នេសាទ បច្ចុប្បន្នផែនការយុទ្ធសាស្ត្រជលផលកំពុងកែសម្រួល ។ លោកស្នើសុំឲ្យលោកភក្តីសង្ខេបដោយខ្លីពីខ្លឹមសារយុទ្ធសាស្ត្ររេដបូកជាតិ ដើម្បីលោកអាចដាក់បញ្ចូលរេដបូកជាផ្នែកមួយនៅក្នុងយុទ្ធសាស្ត្រជលផល ទន្ទឹមនឹងនេះ លោកនឹងសង្ខេបដោយខ្លីពីខ្លឹមសារយុទ្ធសាស្ត្រជលផល ដើម្បីលោកអាចដាក់បញ្ចូលជលផលជាផ្នែកមួយនៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិវិញ។

លោក ប៊ុន រ៉ាស៊ី ៖ សំណូមពរឲ្យមានការពិភាក្សាផ្តល់យោបល់ពីអ្នកពាក់ព័ន្ធ ដើម្បីឲ្យផែនការយុទ្ធសាស្ត្ររេដបូកជាតិយើងអាចទទួលបានការគាំទ្រថវិកា ដូចផែនការយុទ្ធសាស្ត្ររេដបូករបស់ប្រទេសវៀតណាម។

ឯកឧត្តមបណ្ឌិត ជា សំអាង ៖ នឹងមានការពិភាក្សាផ្តល់យោបល់ផ្ទៃក្នុងរបស់ស្ថាប័នអនុវត្តកម្មវិធីមុននឹងឈានទៅដល់ការពិភាក្សាផ្តល់យោបល់ពីស្ថាប័ននិងអ្នកពាក់ព័ន្ធដទៃទៀត។ ឯកឧត្តមបន្ថែមថាយុទ្ធសាស្ត្ររេដបូក

ដែលមានការគាំទ្រពីអន្តរជាតិគឺជាយុទ្ធសាស្ត្រ ដែលរៀបចំឡើងត្រូវនឹងបុព្វបទរបស់ជាតិកម្ពុជាក្នុងការគ្រប់ គ្រងធនធានព្រៃឈើ និងជាយុទ្ធសាស្ត្រដែលដើរស្របនឹងក្របខណ្ឌយុទ្ធសាស្ត្ររដបូកសកល។

សេចក្តីសម្រេច

- លោក ងួន ភក្តី នឹងសង្ខេបដោយខ្លីពីខ្លឹមសារយុទ្ធសាស្ត្ររដបូកជាតិ ដើម្បីអាចដាក់បញ្ចូលរដបូកជាផ្នែកមួយនៅក្នុងយុទ្ធសាស្ត្រជលផល
- លោកអ៊ុកវិបុល នឹងសង្ខេបដោយខ្លីពីខ្លឹមសារយុទ្ធសាស្ត្រជលផលដើម្បីអាចដាក់បញ្ចូលជលផលជាផ្នែកមួយនៅក្នុងយុទ្ធសាស្ត្ររដបូកជាតិ
- សេចក្តីព្រាងបឋមយុទ្ធសាស្ត្ររដបូកជាតិ នឹងធ្វើឲ្យបានចប់នៅត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ នឹងដាក់ជូនក្រុមការងាររដបូកជាតិ ។

<u>២.១.៣ ការបង្កើតកម្រិតបំភាយគោលរដបូកជាតិ</u>

លោក ឡេង ជីវិន អនុប្រធានក្រុមបច្ចេកទេស MRV បានបង្ហាញជូនពីប្រវត្តិខ្លះៗស្តីពីការសិក្សាគម្របព្រៃឈើជាតិ គោលបំណងសំខាន់ និងការប្រើប្រាស់ព័ត៌មានគម្របព្រៃឈើជាតិ និងប្រភពព័ត៌មានដែលអាចរកបាន។ ជាបន្តលោក ឡេង ជីវិន បានបង្ហាញដំណាក់កាលជាបន្តបន្ទាប់នៃការសិក្សាបង្កើតគម្របព្រៃឈើជាតិសម្រាប់រដបូក និងមុខងារសំខាន់២ នៃប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិរបស់រដបូក។ លោកក៏បានលើកឡើងពីកត្តាចាំបាច់នៃការបណ្តុះបណ្តាលដើម្បីកសាងសមត្ថភាពមន្ត្រី និងស្ថាប័នជាតិ ក្នុងការវាស់វែងរាយការណ៍ផ្ទៀងផ្ទាត់ និងតាមដាន ត្រួតពិនិត្យគម្របព្រៃឈើជាតិសម្រាប់រដបូកផងដែរ។ ដោយបានបង្ហាញពីលក្ខណៈបច្ចេកទេសក្នុងការបង្កើតគម្របព្រៃឈើជាតិសម្រាប់រដបូក និងប្រព័ន្ធត្រួតពិនិត្យ លោក ឡេង ជីវិន បានវាយតម្លៃថា កិច្ចការងារនេះត្រូវការចំណេះដឹងផ្នែកបច្ចេកទេសច្បាស់លាស់ មានបទពិសោធន៍ ទាមទារឲ្យមានការអត់ធ្មត់ និងប្រើប្រាស់ពេលវេលាច្រើន(<u>ឧបសម្ព័ន្ធ០៦៖ បទបង្ហាញស្តីពីការបង្កើតកម្រិតបំភាយគោលរដបូកជាតិ</u>)។

<u>ការពិភាក្សា</u>

លោកប៊ុនរ៉ាសុី ៖លើកជាសំណួរថាការរៀបចំកម្រិតបំភាយយោងត្រូវធ្វើក្នុងរយៈពេលប៉ុន្មានឆ្នាំ?

លោក ឡេង ជីវិន ៖ រយៈពេល៣ឆ្នាំ ឬ ៥ឆ្នាំ យើងមានការបកស្រាយគម្របព្រៃឈើម្តង។ ឆ្នាំ២០១៤ គឺជាឆ្នាំគោលទាំងបច្ចេកទេស ទាំងទ្រឹស្តីក្នុងការបកស្រាយគម្របព្រៃឈើសម្រាប់ការអនុវត្តរដបូក។ ដោយឡែកកម្រិតបំភាយយោង គឺយើងពិនិត្យមើលលើអតីតកាលពីនិន្នាការថយចុះគម្របព្រៃឈើ។ ក្រោយពីអនុវត្តរដបូក យើងនឹងផ្ទៀងផ្ទាត់ថាតើគម្របព្រៃឈើមានការថយចុះឬយ៉ាងណា?

ឯកឧត្តមបណ្ឌិត ជា សំអាង ៖ គម្របព្រៃឈើសម្រាប់រដបូកអាចខុសពីគម្របព្រៃឈើទូទៅដោយសារការកំណត់និយមន័យព្រៃឈើខុសគ្នា។ ចំណុចសំខាន់បន្ទាប់ពីការអនុវត្តរដបូក កម្រិតបំភាយឧស្ម័នត្រូវតែថយចុះធៀបនឹងកម្រិតបំភាយយោង មានន័យថាប្រសិនបើកម្រិតបំភាយឧស្ម័នបណ្តាលពីការបាត់បង់ព្រៃឈើមានការកើនឡើងជាការបរាជ័យ។ ឧទាហរណ៍ គម្របព្រៃនៅដដែល ប៉ុន្តែដើមឈើធំៗត្រូវបានដកហូត និងគុណភាពព្រៃឈើមានការថយចុះ ដូច្នេះមានន័យថាកម្រិតបំភាយឧស្ម័នមានការកើនឡើង នេះជាការបរាជ័យរបស់រដបូក។

សេចក្តីសម្រេច

- គាំទ្រការបន្តកិច្ចការងារក្រុមបច្ចេកទេស MRV ក្នុងការរៀបចំបង្កើតកម្រិតបំភាយយោងឲ្យបានទាន់ពេលវេលាដើម្បីដាក់ជូន UNFCCC ស្របតាមក្របខ័ណ្ឌការងារនៃការទូទាត់រដបូកតាមលទ្ធផល។ HJ

២.១.៤ យន្តការសម្របសម្រួលរេដបូកជាតិ

លោកបណ្ឌិត ឃនសារ៉ែត ប្រធានលេខាធិការដ្ឋានរេដបូក បានបង្ហាញជូនពីរចនាសម្ព័ន្ធអភិបាលកិច្ច និងការសម្របសម្រួលរេដបូកនៅកម្ពុជា និងបញ្ជាក់ពីខ្សែសង្វាក់ទំនាក់ទំនងរវាងស្ថាប័ន និងក្រុមការងារ ដែលកំពុងគាំទ្ររេដបូកនៅកម្ពុជា។ ជាបន្ថែមលោកបណ្ឌិតក៏បានលើកឡើងពីពេលវេលាដែលក្រុមអ្នកពាក់ព័ន្ធត្រូវរៀបចំកិច្ចប្រជុំពិភាក្សា ដើម្បីធ្វើឲ្យការសម្របសម្រួល និងសកម្មភាពការងារមានភាពស៊ីសង្វាក់គ្នា(ឧបសម្ព័ន្ធ ០៧៖ បទបង្ហាញស្តីពីយន្តការសម្របសម្រួលរេដបូកជាតិ)។

២.១.៥ បច្ចុប្បន្នភាពស្តីពីការអភិវឌ្ឍរេដបូកនៅថ្នាក់អន្តរជាតិ - កិច្ចប្រជុំកំពូលស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៤, IPCC Report, សេចក្តីព្រាងយុទ្ធសាស្ត្រ UN-REDD និងចំណុចសំខាន់ៗនៃកិច្ចប្រជុំគណកម្មាធិការ UN-REDD Policy Board and FCPF នៅទីក្រុង Arusha, Tanzania

បទបង្ហាញនេះរៀបចំដោយលោក ហ៊ីរ៉ូស៊ី ណាកាតា ប៉ុន្តែដោយសារអវត្តមាន លោក ងួន ភក្តី ជាទីប្រឹក្សាជាតិ ដែលយល់ច្បាស់ពីកិច្ចការនេះ បានបង្ហាញជំនួស។ លោក ងួន ភក្តី បានបញ្ជាក់ថា មានការអភិវឌ្ឍជាច្រើននៅលើសកលលោកឆ្ពោះទៅរក "ការទូទាត់ផ្អែកតាមលទ្ធផល" ។ ឯកសារសំខាន់ៗដែលបានចេញផ្សាយពាក់ព័ន្ធនឹងរេដបូករួមមាន៖ ១)សេចក្តីប្រកាសទីក្រុងញូយ៉ កស្តីពីព្រៃឈើ ២)សេចក្តីថ្លែងការណ៍អំពីសកម្មភាព និងផែនការសកម្មភាព ៣)សេចក្តីថ្លែងការណ៍រួមគ្នារបស់ប្រទេសណរវ៉េ អាល្លឺម៉ង់ និងចក្រភពអង់គ្លេស ស្តីពីការផ្តល់ហិរញ្ញប្បទានដល់កម្មវិធីដែលអាចជឿទុកចិត្តបានចំនួន២០ ដែលស្នើឡើងត្រឹមឆ្នាំ ២០១៦ និង៤)សេចក្តីថ្លែងការណ៍របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន។ លោក ងួន ភក្តី បន្ថែមថា ក្របខ័ណ្ឌយុទ្ធសាស្ត្រថ្មីរបស់កម្មវិធី UN-REDD នឹងបង្កលក្ខណៈឲ្យប្រទេសដែលអនុវត្តកម្មវិធីរេដបូក អាចទទួលបានការទូទាត់ផ្អែកតាមលទ្ធផល។ COP 21 នៅទីក្រុងប៉ារីស រំពឹងថានឹងធ្វើសេចក្តីសម្រេចអំពីក្របខ័ណ្ឌការងាររេដបូកក្រោយឆ្នាំ២០២០។ មូលនិធិអាកាសធាតុបៃតង (Green Climate fund) គឺជាឧបករណ៍សំខាន់សម្រាប់ការទូទាត់ផ្អែកតាមលទ្ធផល។ សហគមន៍អន្តរជាតិកំពុងបោះជំហានទៅរក ការទូទាត់ផ្អែកតាមលទ្ធផល។ កម្ពុជាត្រូវរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលអនុម័តឱ្យបានមុនខែសីហា ឆ្នាំ ២០១៥ និងបង្ហាញសហគមន៍អន្តរជាតិនៅក្នុងកិច្ចប្រជុំ COP 21 ដើម្បីស្នើសុំដាក់បញ្ចូលជាកម្មវិធីមួយ ក្នុងចំណោមកម្មវិធីទាំង២០ ដែលលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍រួមគ្នារបស់ប្រទេសណរវ៉េ អាល្លឺម៉ង់ និងចក្រភពអង់គ្លេស(ឧបសម្ព័ន្ធ០៨៖បទបង្ហាញស្តីពីបច្ចុប្បន្នភាពនៃការអភិវឌ្ឍរេដបូកនៅអន្តរជាតិ)។

សេចក្តីសម្រេច

- លេខាធិការដ្ឋានរេដបូកត្រូវរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិឲ្យបានទាន់ពេលវេលា ដើម្បីដាក់ជូនរាជរដ្ឋាភិបាលអនុម័តឱ្យបានមុនខែសីហាឆ្នាំ២០១៥ និងបង្ហាញសហគមន៍អន្តរជាតិនៅក្នុងកិច្ចប្រជុំ COP 21 នៅទីក្រុងប៉ារីស ។

២.១.៦ ការបង្កើតជម្រើសយន្តការថវិការេដបូក

លោក ឈុនឌីលុច មន្ត្រីបច្ចេកទេសលេខាធិការដ្ឋានរេដបូក បានធ្វើបទបង្ហាញដោយសង្ខេបជម្រាបជូនកិច្ចប្រជុំថា៖ ការបន្តសិក្សាស្តីពីជម្រើសយន្តការថវិការេដបូក ដែលធ្វើឡើងដោយ Ms. Berta Pesti បាន

បញ្ចប់ នឹងបានស្នើឡើងជម្រើសយន្តការថវិកាចំនួន៣៖ 1-Sinking Fund, 2-Revolving Fund និង 3-Endowment Fund។ ក្នុងរបាយការណ៍សិក្សាបានបង្ហាញថា ជម្រើសយន្តការថវិកាទាំងបីនេះ មានគុណសម្បត្តិ និងចំនុចខ្វះខាតដូចគ្នា ប៉ុន្តែ Ms. Berta Pesti បានផ្តល់អនុសាសន៍ថា Revolving Fund មានលក្ខណៈសមស្របនឹងស្ថានភាពកម្ពុជានាពេលបច្ចុប្បន្ន និងមានប្រទេសមួយចំនួនក៏បានជ្រើសរើសយកជម្រើស Revolving Fund នេះផងដែរ។ បន្ទាប់ពីការសម្រេចចិត្តលើជម្រើសយន្តការថវិកា ជំហ៊ានជាបន្តបន្ទាប់ គឺការសម្រេចចិត្តលើ៖ រចនាសម្ព័ន្ធអន្តរកាល(Interim Structure) សមត្ថភាពនីត្យានុកូល(Legal Capacity) អ្នកទទួលការទុកចិត្ត(Trustee)។ ជាជំនួយដល់ការពិចារណា និងការធ្វើសេចក្តីសម្រេចចិត្ត លោក ឈុន ឌីលុច បាន បង្ហាញពីអត្ថន័យ និងកិច្ចការដែលត្រូវធ្វើបន្តសម្រាប់ រចនាសម្ព័ន្ធអន្តរកាល សមត្ថភាពនីត្យានុកូល និងអ្នកទទួលការទុកចិត្ត។ ជាបន្ថែម លោក ឈុនឌីលុច បានបង្ហាញពី ការបង្កើតថវិការេដបូក ការបង្កើតនិតិវិធីលំអិតសម្រាប់ថវិការេដបូក ការកៀរគរប្រមូលថវិការេដបូកប្រតិបត្តិការថវិការេដបូក ការកសាងសមត្ថភាព និងការផ្ទេរភាពជាម្ចាស់ថវិការេដបូកជូនជាតិ ចុងក្រោយ លោក ឈុនឌីលុច បានស្នើសុំឲ្យក្រុមការងាររេដបូកជាតិសម្រេចជ្រើសយកយន្តការថវិកាណាមួយ ដើម្បីឲ្យលេខាធិការដ្ឋានធ្វើកិច្ចការបន្តតាមការសម្រេចនេះ(<u>ឧបសម្ព័ន្ធ ០៩៖បទបង្ហាញស្តីពីការបង្កើតជម្រើសយន្តការថវិការេដបូកជាតិ</u>)។

<u>ការពិភាក្សា</u>

ឯកឧត្តមបណ្ឌិត ជា សំអាង ៖ យន្តការថវិការេដបូកនេះយើងធ្លាប់បានពិភាក្សាម្តងរួចមកហើយ ដោយបានពិចារណាយន្តការថវិកាផ្អែកលើកម្មវិធីជាមូលដ្ឋាន(programme based approach) ដោយប្រមូលថវិកាជំនួយទាំងអស់ដាក់ក្នុងកញ្ចប់តែមួយ ប៉ុន្តែជម្រើសនេះមានផលវិបាកដោយហេតុថាម្ចាស់ជំនួយថវិកានីមួយៗមានគោលនយោបាយ និងតម្រូវការគ្រប់គ្រងថវិកាខុសៗគ្នា។ ថវិកាវិលជុំ(Revolving Fund) មានលក្ខណៈស្រដៀងគ្នាគឺប្រមូលថវិកាជំនួយទាំងអស់ដាក់ក្នុងកញ្ចប់តែមួយ ចំណុចខុសគ្នាគឺមានចំណូលពីទូទាត់សងលទ្ធផលរេដបូក។ ប្រសិនបើយកជម្រើសថវិកាវិលជុំ(Revolving Fund) យើងត្រូវពិភាក្សាជាមួយម្ចាស់ជំនួយថវិកាថាតើអាចដាក់ថវិកាជាកញ្ចប់តែមួយបានដែរឬទេ ប្រសិនបើអាចធ្វើទៅបានវាជាការប្រសើរព្រោះយើងអាចប្រមូលផ្តុំជំនួយថវិការេដបូកដាក់ក្នុងកញ្ចប់តែមួយ។

លោក ឈុនឌីលុច ៖ បញ្ជាក់ថា អ្នកឯកទេសគាត់បានជួបពិភាក្សាជាមួយអ្នកពាក់ព័ន្ធ និងបានសិក្សាលើឯកសារជាច្រើន ដោយរួមផ្សំនិងបទពិសោធន៍ក្នុងការរៀបចំយន្តការថវិការេដបូកនៅប្រទេសមួយចំនួនផងនោះ គាត់គិតថាជម្រើសថវិកាវិលជុំ(Revolving Fund)នេះល្អបំផុត និងអាចអនុវត្តបាន ដោយសារយន្តការថវិកានេះមានលក្ខណៈសមស្របទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ ។

ឯកឧត្តម ជាម ប៉េអា ៖ ជូនព័ត៌មានថា រដ្ឋាភិបាលបានពិចារណាបន្ថែមពន្ធលើស្រា និងបារី ដើម្បីនឹងអាចបង្កើនថវិកា៥លានដុល្លា សម្រាប់ចែកជូនមន្ទីរបរិស្ថានរាជធានី-ខេត្តប្រមាណ២៥ម៉ឺនដុល្លាក្នុង១ឆ្នាំ សម្រាប់ការគ្រប់គ្រងសំរាម និងកាកសំណល់រឹងរាវ។ ប្រសិនបើយើងអាចសិក្សាបានច្បាស់លាស់ពីការបង្កើនចំណូលពន្ធពីដីសម្បទានសេដ្ឋកិច្ចឲ្យបានសមស្រប ដើម្បីបន្ថែមថវិកាសម្រាប់ការការពារ និងអភិរក្សព្រៃឈើកាបូនស្តុក យើងរំពឹងថារាជរដ្ឋាភិបាលនឹងមានការគាំទ្រ។ បើយើងពឹងផ្អែកតែលើថវិកាជំនួយ យើងនឹងមានការលំបាក មិនអាចបត់បែនតាមស្ថានភាពរបស់យើងបានឡើយ ដោយសារតែម្ចាស់ជំនួយនីមួយៗមានគោលនយោបាយ និងលក្ខខណ្ឌផ្សេងគ្នា។ តាមការយល់ដឹងពីទស្សនកិច្ចសិក្សាកន្លងមកនៅប្រទេសវៀតណាម ថវិកាអនុវត្តកម្មវិធីមួយផ្នែកបានពីចំណូលពន្ធពីវិស័យឧស្សាហកម្មបន្ថែមលើថវិកាជំនួយដែលកម្មវិធីមាន។ HS

លោក គឹម ណុង ៖ ក្រសួងបរិស្ថានគ្រាន់តែជាអ្នកកៀរគរថវិកា និងផ្ទេរជូនថវិកាទៅឲ្យបរិស្ថានរាជធានី ខេត្តដើម្បីអនុវត្ត។ ប្រសិនបើការអនុវត្តមានតម្លាភាព និងទទួលបានលទ្ធផលល្អ ក្រសួងនឹងស្វះស្វែងរកថវិកា បន្ថែមទៀត។ លោក គឹម ណុង បានលើកឡើងពីថវិការបស់គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ(CCCA) ដែលអាចស្នើសុំយកទៅអនុវត្តបានដោយស្ថាប័នរដ្ឋាភិបាល ឬ អង្គការមិនមែនរដ្ឋាភិបាល និងមានគណកម្មាធិ ការគ្រប់គ្រងថវិកាដែលមានសមាជិកមកពីរដ្ឋាភិបាលនិងម្ចាស់ជំនួយឬតំណាង។

លោក ឈុំ សុវណ្ណនី ៖ ជូនព័ត៌មានបន្ថែមថា ថវិការបស់គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ (CCCA) ជំហានទី២ មានប្រមាណជា១៣លានដុល្លាអាមេរិក ទទួលបានពីស៊ុយអែត និងសហគមន៍អឺរុប។ បច្ចុប្បន្ន កំពុងដំណើការរៀបចំផែនការសកម្មភាពគម្រោងឲ្យស្របតាមយុទ្ធស្រាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

លោក អ៊ុយ កាម៉ាល ៖ ថវិកា CCCA មានទម្រង់ជា Sinking Fund ដែលបានកៀគរថវិកាដាក់ជាកញ្ចប់ រួមមួយ និងមានគណកម្មាធិការគ្រប់គ្រងថវិកាជាសមាជិកមកពីគណកម្មាធិការជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលមកពីក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍដែលជាម្ចាស់ជំនួយរួមទាំង UNDP ផងដែរ។ បច្ចុប្បន្នក្រសួងបរិស្ថាន កំពុងពិចារណាក្នុងការបង្កើត CCCA Trust Fund ប៉ុន្តែរូបរាងយ៉ាងណាយើងមិនទាន់ដឹងច្បាស់នៅឡើយទេ។

ឯកឧត្តម នេត មុន្នី៖ ពាក់ព័ន្ធនិងជម្រើសយន្តការថវិការដបូកគួរមានជាដំណាក់កាល ដោយចាប់ផ្តើមជំហាន ដំបូងពី Sinking Fund និងបន្តដោយ Revolving Fund ។ នៅពេលដែលយើងមានចំណូលថវិកាដែលបានពី ការលក់កាបូន គឺត្រូវមានច្បាប់គ្រប់គ្រង ដោយសារនេះជាចំណូលថវិកាជាតិ។

ឯកឧត្តមបណ្ឌិត ជា សំអាង ៖ ប្រសិនបើឈានទៅដល់ការលក់កាបូន នោះនឹងមានការស្មុគស្មាញ និងមាន ការទទួលខុសត្រូវខ្ពស់ ព្រោះជាការលក់ទ្រព្យសម្បត្តិរដ្ឋ នឹងមានការទទួលខុសត្រូវបន្តជំនាន់។ ឯកឧត្តមឯកភាព នឹងយោបល់ អនុវត្តយន្តការថវិការដបូកជាដំណាក់កាលដោយចាប់ផ្តើមពី Sinking Fund ចំនួន២ឬ៣ឆ្នាំ និងបន្ត ដោយ Revolving Fund ប៉ុន្តែឥឡូវនេះយើងមិនទាន់ច្បាស់ផង ថាតើការគ្រប់គ្រង និងអនុវត្ត Sinking Fund ដោយ របៀបណា។

លោក ឈុនឌីលុច ៖ ដោយសារសន្មត់ថា Revolving Fund ជាជម្រើសល្អបំផុតនោះ ដូច្នេះការសិក្សាពី យន្តការអនុវត្តនិងការគ្រប់គ្រង នៅផ្នែកជាបន្តបន្ទាប់ ដែលសរសេរដោយអ្នកឯកទេស បានផ្តោតសំខាន់តែលើ Revolving Fund ប៉ុណ្ណោះ។

ឯកឧត្តមបណ្ឌិត ជា សំអាង ៖ សំណូមពរឲ្យអ្នកឯកទេសសរសេរឲ្យបានលំអិតពី Sinking Fund និង Revolving Fund ដើម្បីយកទៅបង្ហាញដៃគូអភិវឌ្ឍ ឬ ម្ចាស់ជំនួយ ពីជម្រើសយន្តការថវិកា ដែលយើងនឹងអនុវត្តជា ដំណាក់កាល។

<u>សេចក្តីសម្រេច</u>

- សំណូមពរឲ្យអ្នកឯកទេសសរសេរឲ្យបានលំអិតពី Sinking Fund និង Revolving Fund ដើម្បីយក ទៅបង្ហាញដៃគូអភិវឌ្ឍឬម្ចាស់ជំនួយ ពីជម្រើសយន្តការថវិកា ដែលយើងនឹងអនុវត្តជាដំណាក់កាល។
- យន្តការថវិការដបូកត្រូវចាប់ផ្តើមពី Sinking Fund ប៉ុន្តែនៅពេលដែលយើងមានចំណូលថវិកាបាន មកពីប្រភពដទៃទៀតដូចជា ថវិកាបានពីការទូទាត់ផ្អែកតាមលទ្ធផល យើងនឹងអនុវត្តតាមជម្រើស យន្តការថវិកា Revolving Fund ។

២.២ វឌ្ឍនភាពក្រោយកិច្ចប្រជុំលើកទី៥

២.២.១ ក្រុមយេនឌ័ររេដបូក

លោក ញ៉ែម សុវណ្ណា ទីប្រឹក្សាគម្រោង FCPF បានបង្ហាញថា ក្រុមយេនឌ័ររេដបូក បានបង្កើតឡើងនៅខែសីហា ឆ្នាំ២០១៤ ដោយមានសមាជិកជាមន្ត្រីរដ្ឋាភិបាលចំនួន ៤រូប (ស្រី៣ ប្រុស១) មកពីក្រសួងកិច្ចការនារី រដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ និងរដ្ឋបាលជលផល។ ក្រុមយេនឌ័ររេដបូកមានតួនាទី បង្កើនការយល់ដឹងអំពីយេនឌ័រពាក់ព័ន្ធនឹងរេដបូក និងជួយផ្តល់យោបល់ជូនក្រុមបច្ចេកទេស និងអ្នកពាក់ព័ន្ធ ដើម្បីបញ្ចូល និងដោះស្រាយបញ្ហាយេនឌ័រ ក្នុងការរៀបចំយុទ្ធសាស្ត្រ និងការអនុវត្តរេដបូក។ ក្រុមការងារយេនឌ័រទទួលបានការបណ្តុះបណ្តាលស្តីពីយេនឌ័រពាក់ព័ន្ធនឹងរេដបូក និងកំពុងរៀបចំ វិធីសាស្ត្រ និងឯកសារសម្រាប់ការបណ្តុះបណ្តាលបន្តជូនក្រុមបច្ចេកទេស និងអ្នកពាក់ព័ន្ធ(ឧបសម្ព័ន្ធ១០៖បទបង្ហាញស្តីពីក្រុមយេនឌ័ររេដបូក)។

ការពិភាក្សា

ឯកឧត្តមបណ្ឌិត ជា សំអាង ៖ សំណូមពរឲ្យអញ្ជើញសមាជិកក្រុមយេនឌ័រទាំងអស់មកចូលរួមកិច្ចប្រជុំ ដើម្បីបង្ហាញពីវឌ្ឍនភាពការងារយេនឌ័ររបស់ខ្លួន។

លោក ប៊ុន រ៉ាស៊ី ៖ ការបង្ហាញពីក្រុមយេនឌ័ររេដបូក មិនបានផ្តល់ព័ត៌មានពីគោលបំណងច្បាស់លាស់ពីការបង្កើតក្រុមនេះ។

លោក លន់ គឹមហ៊ី ៖ នៅកិច្ចប្រជុំលើកទី៥ក្រុមការងាររេដបូកកម្ពុជា យើងបានជម្រាបជូនពីហេតុផលគោលបំណង លក្ខខណ្ឌការងារ និងសុំការគាំទ្រពីកិច្ចប្រជុំដើម្បីបង្កើតក្រុមយេនឌ័រ ហេតុដូច្នេះកិច្ចប្រជុំនេះយើងមិនបានរំលឹកចំណុចទាំងអស់នេះឡើងវិញទេ គឺគ្រាន់តែជម្រាបជូនពីវឌ្ឍនភាពពីការបង្កើតក្រុម និងសកម្មភាពអនុវត្តដែលសម្រេចបានដូចមានក្នុងស្លាយ។

សេចក្តីសម្រេច

- កិច្ចប្រជុំក្រុមការងាររេដបូកកម្ពុជាលើកក្រោយៗ លេខាធិការដ្ឋានត្រូវអញ្ជើញក្រុមយេនឌ័រទាំងបួននាក់មកចូលរួមដើម្បីបង្ហាញពីវឌ្ឍនភាពការងារយេនឌ័រ ។

២.២.២ ផ្នែកទំនាក់ទំនង និងព័ត៌មាន

លោក លន់ គឹមហ៊ី បានបង្ហាញថា ការងារផ្នែកទំនាក់ទំនង និងព័ត៌មានរេដបូកមានវឌ្ឍភាពជាធម្មតា ទោះបីជាមន្ត្រីផ្នែកទំនាក់ទំនងអវត្តមានក៏ដោយ។ កន្លងមកលេខាធិការដ្ឋានបានធ្វើកិច្ចសន្យាជាមួយកម្មវិធីទូរទស្សន៍ជាតិ ដើម្បីរៀបចំកម្មវិធីវេទិកាសំណួរចម្លើយរេដបូកចំនួន១០ប្រធានបទ ក្នុងនេះ២ប្រធានបទ បានថត និងផ្សព្វផ្សាយ។ ដោយឡែកកម្មវិធីវិទ្យុ បានធ្វើកិច្ចសន្យាជាមួយវិទ្យុស្ត្រី ១០២ (FM) ដើម្បីផ្សព្វផ្សាយតាមកម្មវិធីរេដបូកតាមប្រព័ន្ធផ្សាយសម្លេង។ ផែនការជំហានទី១ ដែលមានកម្មវិធីសំណួរចម្លើយចំនួន៨ប្រធានបទ វីដេអូស្តុត១រឿង និងគ្រាម៉ា២រឿង បានរៀបចំ និងអនុម័ត។ បច្ចុប្បន្នកំពុងត្រៀមរៀបចំឯកសារ ដើម្បីគាំទ្រវាគ្មិនក្នុងការចូលរួមក្នុងកម្មវិធីសំណួរចម្លើយតាមវិទ្យុ។ សម្ភារៈអប់រំផ្សព្វផ្សាយស្តីពីរេដបូកផ្សេងទៀតដូចជា៖ ការផលិតវីដេអូខ្លី ផ្ទាំងរូបភាព ខិតប័ណ្ណ ទស្សនាវដ្តី កូនសៀវភៅកត់ត្រាសេច ក្តីសម្រេចCOP និងកូនសៀវភៅសន្ទានុក្រមរេដបូក កំពុងដំណើរការផលិត។ (ឧបសម្ព័ន្ធ១១៖បទបង្ហាញស្តីពីផ្នែកទំនាក់ទំនង និងព័ត៌មាន)។

ការពិភាក្សា

លោក អ៊ុយ កាម៉ាល ៖ សារ និងព័ត៌មាន ដែលបានរៀបចំសម្រាប់កម្មវិធីទូរទស្សន៍ កម្មវិធីវិទ្យុ ព្រឹត្តិប័ត្រ និងសម្ភារៈផ្សព្វផ្សាយ បានឆ្លងកាត់កិច្ចប្រជុំក្រុមបច្ចេកទេស ដើម្បីពិនិត្យអត្ថន័យ នឹងខ្លឹមសាររួចហើយ និងទទួលស្គាល់ថាអាចទទួលយកបាន ប៉ុន្តែឃ្លាឃ្លោងដែលសរសេរជាភាសាជាតិ(ខ្មែរ) មានភាពឆ្គាំឆ្គងជាច្រើន ពិបាកយល់និងអាចមានការភ័ន្តច្រឡំ ដែលចាំបាច់ត្រូវមានការកែសម្រួលឲ្យបានសមរម្យ មុននឹងយកទៅផ្តល់បទសម្ភាសន៍ក្នុងកម្មវិធីវិទ្យុ ទូរទស្សន៍ ឬ ការបោះពុម្ពផ្សព្វផ្សាយ។ ជាសំណូមពរ គួរមានក្រុមអ្នកកែសម្រួលសម្រាប់លេខាធិការដ្ឋាន ដើម្បីជួយពិនិត្យកែសម្រួលអត្ថបទ ដែលរំពឹងថានឹងអាចទទួលយកបាននៅពេលបោះពុម្ពផ្សព្វផ្សាយ។

លោក អ៊ុក វិបុល ៖ កន្លងមកលោកមិនបានទទួលឯកសារព្រាងសេចក្តីសម្រេច COP និងសន្ធានុក្រមរេដបូក ដើម្បីពិនិត្យកែសម្រួលទេ ដូច្នេះសូមលេខាធិការដ្ឋានត្រូវធ្វើជាថ្មីម្តងទៀត លោកនឹងជួយពិនិត្យកែសម្រួលលើឯកសារទាំង២នេះ។

សេចក្តីសម្រេច

- លេខាធិការដ្ឋានត្រូវធ្វើជាថ្មីម្តងទៀត លោកនឹងជួយពិនិត្យកែសម្រួលលើឯកសារទាំង២នេះ
- លេខាធិការដ្ឋានត្រូវពិនិត្យកែសម្រួលអត្ថបទឃ្លាឃ្លោងឲ្យបានសមស្រប និងដាក់ជូនអ្នកពាក់ព័ន្ធពិនិត្យមុននឹងយកទៅបោះពុម្ព ឬ ផ្សព្វផ្សាយ
- លេខាធិការដ្ឋានត្រូវពិចារណាពីការរៀបចំ និងការគាំទ្រឲ្យមាក្រុមអ្នកកែសម្រួល។

<u>២.២.៣ ការបង្កើតជម្រើសចែករំលែកផលប្រយោជន៍រេដបូក</u>

លោក ហេង ហុង អនុប្រធានក្រុមបច្ចេកទេសចែករំលែកផលប្រយោជន៍រេដបូក បានធ្វើបទបង្ហាញពីលទ្ធផលនៃការសិក្សា និងការប្រឹក្សាយោបល់នៅថ្នាក់ខេត្ត ស្តីពីជម្រើសនៃការចែករំលែកផលប្រយោជន៍។ លោក ហេង ហុង បញ្ជាក់ថា ប្រសិទ្ធភាព(Effective) ប្រសិទ្ធផល(Efficiency) និងសមធម៌(Equity) គឺជាគោលការណ៍សំខាន់សម្រាប់ការចែករំលែកផលប្រយោជន៍។ ផលប្រយោជន៍រេដបូក អាចទទួលបានជាសាច់ប្រាក់ និងមិនមែនជាសាច់ប្រាក់។ ផលប្រយោជន៍រេដបូកមិនមែនជាសាច់ប្រាក់ អាចជាអត្ថប្រយោជន៍ផ្ទាល់ដូចជា៖ ផ្តល់ឱកាសការងារ ជួយបង្កើនជីវភាព ផ្តល់អនុផលព្រៃឈើ ផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងធ្វើឲ្យប្រសើឡើងប្រព័ន្ធអេកូឡូស៊ី។ល។ ដោយឡែក អត្ថប្រយោជន៍មិនផ្ទាល់ អាចជា៖ ការធ្វើឲ្យអភិបាលកិច្ចព្រៃឈើប្រសើរឡើង និងការបង្កើនការចូលរួមពីភាគីពាក់ព័ន្ធកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ អ្នកពាក់ព័ន្ធសំខាន់ក្នុងការបែងចែកផលប្រយោជន៍រេដបូករួមមាន៖ សហគមន៍មូលដ្ឋានដែលរួមមានជនជាតិដើមភាគតិច អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងរាជរដ្ឋាភិបាល។ សំណួរគន្លឹះដែលបានពិភាក្សានៅក្នុងកិច្ចប្រជុំពិភាក្សាថ្នាក់ជាតិ និងថ្នាក់ខេត្តទាំង១០រួមមាន៖ តើសកម្មភាពអ្វីខ្លះដែលត្រូវផ្តល់ការគាំទ្រ? តើអ្នកណាអាចមានលក្ខណៈសម្បត្តិដើម្បីទទួលផលប្រយោជន៍? តើការបែងចែកផលប្រយោជន៍ត្រូវផ្អែកលើមូលដ្ឋានអ្វីខ្លះ? តើផលប្រយោជន៍អ្វីខ្លះ គួរធ្វើការបែងចែក? ដើម្បីមានមូលដ្ឋានសម្រាប់ការពិភាក្សា លោក ហេង ហុង ក៏បានបង្ហាញផងដែរពីចំណាយរេដបូកដូចជា៖ ចំណាយប្រតិបត្តិការ រដ្ឋបាល ចំណាយលើការរៀបចំបែបបទនិងចំណាយសម្រាប់ការអនុវត្តសកម្មភាពសំខាន់ៗដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ<u>(ឧបសម្ព័ន្ធ១២៖ បទបង្ហាញស្តីពីជម្រើសចែករំលែកផលប្រយោជន៍រេដបូក)</u>។

ការពិភាក្សា

លោក ប៊ុន រ៉ាស៊ី ៖ តាមការសិក្សាតើមានមុខរបរណាដែលអាចជួយឲ្យសហគមន៍អាចទទួលប្រយោជន៍ និងអាចចូលរួមបានក្នុងការអនុវត្តរេដបូក ឧទាហរណ៍តំបន់ណាគួរធ្វើអ្វីខ្លះ។

លោក ហេង ហុង ៖ កិច្ចប្រជុំពិភាក្សាទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្តគឺប្រើប្រាស់សំនួរជាទូទៅ មិនបានផ្តោតសំនួរជាក់លាក់ថាតំបន់ណាត្រូវប្រកបមុខរបរអ្វី ដើម្បីឲ្យមាននិរន្តរភាពក្នុងការគ្រប់គ្រងធនធានធម្មជាតិឡើយ។ យ៉ាងណាក៏ដោយ សហគមន៍បានផ្តល់យោបល់ថាការបែងចែកផលប្រយោជន៍គួរគិតជាភាគរយ និងមានយោបល់ជាច្រើនទៀត ដែលក្រុមបច្ចេកទេសកំពុងគិតគូរពិចារណាសម្រាប់ការរៀបចំសម្រាប់ការបែងចែកផលប្រយោជន៍រេដបូក។ ផ្អែកតាមបទពិសោធន៍ការងារសហគន៍ព្រៃឈើ ពាក់ព័ន្ធនឹងមុខរបរគឺមានការផ្លាស់ប្តូរពីតំបន់មួយទៅតំបន់មួយទៀត។

លោក ចាន់សុភាព ៖ ការចុះពិភាក្សាយោបល់កន្លងមកបានផ្តោតសំខាន់លើការបង្កើនការយល់ដឹងពីគោលការណ៍ និងអ្នកទទួលផលពីការបែងចែកផលប្រយោជន៍រេដបូក ព្រមពេលជាមួយគ្នានេះក្រុមបច្ចេកទេសប្រមូលមតិយោបល់ពីអ្នកពាក់ព័ន្ធថាតើការបែងចែកផលប្រយោជន៍ដោយរបៀបណា ដោយប្រើសំនួរដូចមាននៅក្នុងបទបង្ហាញ។

លោកបណ្ឌិត កែវ អូម៉ាលីស្ស ៖ ការសិក្សាពីការបែងចែកផលប្រយោជន៍ជាកិច្ចការងារសំខាន់ ដើម្បីកំណត់នូវលក្ខណៈវិនិច្ឆ័យជាក់លាក់ស្តីពីការបែងចែកផលប្រយោជន៍រេដបូក ដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ។ ឧទាហរណ៍ ម្ចាស់កម្មសិទ្ធលើកាបូន រហូតមកដល់ពេលនេះយើងមិនទាន់ដឹងច្បាស់នៅឡើយថាតើនណាជាម្ចាស់កម្មសិទ្ធកាបូន ដូចជាសហគមន៍ព្រៃឈើថាតើគាត់ជាម្ចាស់កម្មសិទ្ធពេញលេញលើកាបូនដែរឬទេ? សហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីដីសហគន៍ តើគាត់មានសិទ្ធកម្រិតណាលើកាបូននិងព្រៃឈើនៅក្នុងដីសហគមន៍ដែលបានចុះបញ្ជី។ នៅឥណ្ឌូណេស៊ី មានការសរសេរច្បាស់ពីភាគរយនៃការបែងចែកប្រយោជន៍ ចំណុចនេះសំខាន់ព្រោះថាអ្នកផ្តល់ជំនួយ កំពុងចាំមើលពីភាពច្បាស់លាស់នៃការបែងចែកប្រយោជន៍ នេះថាតើមានសមធ៌ម និងមានតម្លាភាពកម្រឹតណា តើការបែងចែកផលប្រយោជន៍នេះធ្វើឲ្យប្រសើឡើងនូវអភិបាលកិច្ចព្រៃឈើដែរឬទេ។ ដូច្នេះក្រុមបច្ចេកទេសត្រូវសិក្សា និងរៀនចំឯកសារនេះឲ្យបានស៊ីជម្រៅសម្រាប់ដាក់បញ្ចូលក្នុងយុទ្ធសាស្ត្ររេដបូកជាតិ។

ឯកឧត្តមបណ្ឌិត ជា សំអាង ៖ ការបែងចែកផលប្រយោជន៍រេដបូកមិនអាចបែងចែកជូនបុគ្គលបានទេ អាចជាការបែងចែកដល់សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល ឬ ក្រុមប្រឹក្សា ដើម្បីបង្កើតសមិទ្ធផលដូចជាសេវា ឬ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសម្រាប់បំរើផលប្រយោជន៍សហគមន៍ឬសាធារណៈ ដូច្នេះបុគ្គលអាចទទួលបានផលប្រយោជន៍ពីសមិទ្ធផលទាំងនេះ។ ដោយឡែកការគ្រប់គ្រងព្រៃឈើ ការបែងចែកផលប្រយោជន៍នឹងអាចចែកជូនដល់ស្ថាប័នដែលមានសមត្ថកិច្ច មានផែនការច្បាស់លាស់ និងមានសមត្ថភាពក្នុងការគ្រប់គ្រងព្រៃឈើ ចំណុចនេះចង់បញ្ជាក់ថា ការបែងចែកផលប្រយោជន៍នេះឲ្យមានប្រសិទ្ធិភាព។ ដូច្នេះបុគ្គលដែលចូលរួមសកម្មភាពគ្រប់គ្រងថែរក្សាការពារព្រៃឈើនឹងទទួលបានផលប្រយោជន៍ពីការចូលរួមសកម្មភាពនេះ។ ការកំណត់ភាគរយលើការបែងចែកផលប្រយោជន៍ អាចធ្វើទៅបានវាលែងតែមានការបែងចែកការគ្រប់គ្រងព្រៃឈើដាច់ពីគ្នា ដូចជានៅប្រទេសឡាវជាដើម ដូច្នេះការយកបទពិសោធន៍ពីប្រទេសដទៃគួរពិចារណាពីស្ថានភាពខុសគ្នាផងដែរ។

លោកសៅ ភារី ៖ ការបែងចែកផលប្រយោជន៍ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ ប្រសិនបើបែងចែកបានត្រឹមត្រូវវាជាកត្តាជម្រុញជួយឲ្យប្រសើឡើង ផ្ទុយមកវិញ បើការបែងចែកផលប្រយោជន៍មិនបានត្រឹមត្រូវនឹងនាំឲ្យអន្តរាយ។

សហគមន៍ព្រៃឈើ គឺជាការប្រគល់សិទ្ធិទៅឲ្យសហគមន៍ប្រើប្រាស់គ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព ប៉ុន្តែទាំងដី ទាំងព្រៃឈើ គឺជាកម្មសិទ្ធិរបស់រដ្ឋ។ ដោយឡែក ដីសហគមន៍ជនជាតិដើមភាគតិច ពិតមែនថាដីត្រូវបានចុះបញ្ជីជាកម្មសិទ្ធរបស់សហគមន៍ ប៉ុន្តែធនធានព្រៃឈើ នៅតែជាទ្រព្យសម្បត្តិរបស់រដ្ឋ ដូច្នេះការសិក្សាពីការបែងចែកផលប្រយោជន៍រេដបូកត្រូវគិតគូរពិចារណាឲ្យបានច្បាស់ពីបញ្ហាទាំងនេះ។

ឯកឧត្តមបណ្ឌិត ជា សំអាង ៖ ព្រៃឈើដែលស្ថិតនៅក្នុងដីដែលបានចុះបញ្ជីកម្មសិទ្ធិជាដីសហគមន៍ជនជាតិដើមភាគតិច គឺមានចំនួនតិចតួចមិនមានផលប៉ះពាល់ជាសំខាន់ដ៏រេដបូកឡើយ ប៉ុន្តែព្រៃឈើទូទៅដែលជនជាតិដើមភាគតិចប្រើប្រាស់ពឹងពាក់អាស្រ័យផលនោះទេដែលសំខាន់ចាំបាច់ឲ្យមានការចូលរួមថែរក្សាការពារ និងទទួលបាននូវការគិតគូរពីការបែងចែកផលប្រយោជន៍រេដបូក ប៉ុន្តែមិនមែនបែងចែកឲ្យបុគ្គលឡើយ។

<u>សេចក្តីសម្រេច</u>

- ការសិក្សាស្តីពីការបែងចែកផលប្រយោជន៍រេដបូកត្រូវធ្វើឲ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយសម្រាប់ការដាក់បញ្ចូលក្នុងយុទ្ធសាស្ត្ររេដបូកជាតិ។

<u>២.២.៤ ការបង្កើតប្រព័ន្ធធានាសុវត្ថិភាពរេដបូក</u>

លោក ឈុនឌីលុច មន្ត្រីបច្ចេកទេសលេខាធិការដ្ឋានរេដបូកបានធ្វើបទបង្ហាញពីលទ្ធផលនៃការសិក្សារៀបចំប្រព័ន្ធធានាសុវត្ថិភាពរេដបូកកម្ពុជា។ បន្ទាប់ពីបានបង្ហាញពីទស្សនទានប្រព័ន្ធធានាសុវត្ថិភាពរេដបូក លោក ឈុន ឌីលុច បញ្ជាក់ថាតម្រូវការសំខាន់ៗរបស់ UNFCCC គឺ៖ ១)ការអភិវឌ្ឍប្រព័ន្ធធានាសុវត្ថិភាពរេដបូក មាន៣ជំហាន និង ២)ប្រព័ន្ធពត៌មានអំពីប្រព័ន្ធធានាសុវត្ថិភាព ក៏មាន៣ជំហានដែរ ។ រហូតមកដល់ពេលនេះយើងបានបញ្ចប់ជំហានទី១(កំណត់គោលការណ៍ និងលក្ខណៈវិនិច្ឆ័យសំខាន់ៗនៃប្រព័ន្ធធានាសុវត្ថិភាព) ជំហានទី២(ការវិភាគកង្វះចន្លោះគោលនយោបាយ ច្បាប់ បទបញ្ញត្តិនៃសង្គម និងបរិស្ថាន និងនីតិវិធី) និងជំហានទី៣(ការជ្រើសរើសគោលនយោបាយ ច្បាប់ បទបញ្ញត្តិ និងការបង្កើតថ្មីតាមសេចក្តីត្រូវការ)។ បច្ចុប្បន្នយើងកំពុងចាប់ផ្តើមជំហានទី៤ គឺការកំណត់សូចនាករសម្រាប់អនុវត្តរេដបូកលើសង្គមនិងបរិស្ថាន។ ដោយឡែក ជំហានទី៥ (ការបង្កើតវិធីសាស្ត្រ ត្រួតពិនិត្យ និងស្ថាប័នទទួលខុសត្រូវ) និងជំហានទី៦ (ការបង្កើតវិធីសាស្ត្ររាយការណ៍ និងការទទួលខុសត្រូវ) យើងរំពឹងថានិងអាចបញ្ចប់ក្នុងឆ្នាំ២០១៥(<u>ឧបសម្ព័ន្ធ១៣៖ បទបង្ហាញស្តីពីការបង្កើតប្រព័ន្ធធានាសុវត្ថិភាពរេដបូក</u>)។

<u>ការពិភាក្សា</u>

ឯកឧត្តមបណ្ឌិត ជា សំអាង ៖ កោតសសើចំពោះក្រុមបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាព ដែលបានសិក្សានិងព្រាងរៀបចំបង្កើតប្រព័ន្ធធានាសុវត្ថិភាពរេដបូកកម្ពុជា និងគាំទ្រលទ្ធផលដែលសម្រេចបានកន្លងមក។

<u>សេចក្តីសម្រេច</u>

- ក្រុមបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពត្រូវបន្តជំហាន(ទី៤ ទី៥ និងទី៦) ដែលនៅសល់ ដើម្បីបង្កើតប្រព័ន្ធព័ត៌មានប្រព័ន្ធធានាសុវត្ថិភាពរេដបូកកម្ពុជា ទៅតាមផែនការការងារឆ្នាំ២០១៥។

២-បញ្ហាផ្សេងៗ

តំណាងក្រុមបច្ចេកទេសទាំងបួនក្រុមបានស្នើសុំឲ្យមានការផ្តល់កាតទូរស័ព្ទដល់សមាជិកក្រុមបច្ចេកទេសក្នុងម្នាក់៣០ដុល្លាសម្រាប់រយៈពេល១ខែ ដើម្បីជួយកាត់បន្ថយការចំណាយថវិកាបុគ្គលផ្ទាល់ខ្លួនដែលបាន

ចំណាយកន្លងមក ក្នុងការទំនាក់ទំនងតាមទូរស័ព្ទ និងចែករំលែកព័ត៌មានតាមរយៈសារអេឡិកត្រូនិក(Email) នៅក្នុងក្រុមការងារ ក៏ដូចជាការទំនាក់ទំនងជាមួយលេខាធិការដ្ឋាន ដើម្បីធ្វើសម្រេចលទ្ធផលការងារបច្ចេកទេសរេដបូកតាមផែនការគ្រោងទុក។

ការពិភាក្សា

ឯកឧត្តមបណ្ឌិត ជា សំអាង ៖ សូមអរគុណដល់សមាជិកក្រុមបច្ចេកទេសទាំងអស់ដែលបានចំណាយថវិកាបុគ្គលផ្ទាល់ខ្លួនកន្លងមក ក្នុងការទំនាក់ទំនង ដើម្បីហេតុផលការងារក្រុមបច្ចេកទេស។ គម្រោង FCPF គួរពិនិត្យពិចារណា និងរៀបចំការគាំទ្រថវិកាដើម្បីទិញកាតទូរស័ព្ទផ្តល់ជូនក្រុមបច្ចេកទេសតាមសំណូមពរ។

សេចក្តីសម្រេច

- ត្រូវពិនិត្យ និងរៀបចំការគាំទ្រថវិកាដើម្បីផ្តល់កាតទូរស័ព្ទដល់ក្រុមបច្ចេកទេសតាមសំណូមពរ
- កិច្ចប្រជុំលើកទី៧ នឹងរៀបចំនៅខែមីនា ឆ្នាំ២០១៥ នៅក្រុងព្រះសីហនុ ដោយឡែកកាលបរិច្ឆេទ និងទីកន្លែងជាក់លាក់នៃកិច្ចប្រជុំនិងជូនដំណឹងនៅពេលក្រោយ។

៤-មតិបូកសរុបបិទអង្គប្រជុំ

ឯកឧត្តមបណ្ឌិត ជា សំអាង ជាប្រធានអង្គប្រជុំ បានបូកសរុបនូវការសម្រេចសំខាន់ៗក្នុងកិច្ចប្រជុំរួមមាន៖

- លេខាធិការដ្ឋាន ត្រូវរៀបចំផែនការកសាងសមត្ថភាពដោយសហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលនៅថ្នាក់ខេត្ត
- លេខាធិការដ្ឋានរៀបចំកម្មវិធី វិធីសាស្ត្រ និងឯកសាររេដបូក និងចុះអនុវត្តការបណ្តុះបណ្តាលដោយមានមន្ត្រីបច្ចេកទេសទាំងបួននាក់មកពីក្រសួងមហាផ្ទៃ ជួយសម្របសម្រួលជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលនៅថ្នាក់ខេត្ត ដើម្បីអនុវត្តកម្មវិធីបណ្តុះបណ្តាលរេដបូក
- លោក ងួន ភក្តី នឹងសង្ខេបដោយខ្លីពីខ្លឹមសារយុទ្ធសាស្ត្ររេដបូកជាតិ ដើម្បីអាចដាក់បញ្ចូលរេដបូកជាផ្នែកមួយនៅក្នុងយុទ្ធសាស្ត្រជលផល
- លោក អ៊ុក វិបុល នឹងសង្ខេបដោយខ្លីពីខ្លឹមសារយុទ្ធសាស្ត្រជលផល ដើម្បីអាចដាក់បញ្ចូលជលផលជាផ្នែកមួយនៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ
- សេចក្តីព្រាងបថមយុទ្ធសាស្ត្ររេដបូកជាតិ នឹងធ្វើឲ្យបានចប់នៅត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ នឹងដាក់ជូនក្រុមការងាររេដបូកជាតិ
- គាំទ្រការបន្តកិច្ចការងារក្រុមបច្ចេកទេស MRV ក្នុងការរៀបចំបង្កើតកម្រិតបំភាយយោងឲ្យបានទាន់ពេលវេលាដើម្បីដាក់ជូន UNFCCC ស្របតាមក្របខ័ណ្ឌការងារនៃការទូទាត់រេដបូកតាមលទ្ធផល
- លេខាធិកាដ្ឋានរេដបូកត្រូវរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិឲ្យបានទាន់ពេលវេលាដើម្បីដាក់ជូនរាជរដ្ឋាភិបាលអនុម័តឱ្យបានមុនខែសីហាឆ្នាំ២០១៥ និងបង្ហាញសហគមន៍អន្តរជាតិនៅក្នុងកិច្ចប្រជុំ COP 21 នៅទីក្រុងប៉ារីស
- សំណូមពរឲ្យអ្នកឯកទេសសរសេរឲ្យបានលំអិតពី Sinking Fund និង Revolving Fund ដើម្បីយកទៅបង្ហាញដៃគូអភិវឌ្ឍ ឬ ម្ចាស់ជំនួយពីជម្រើសយន្តការថវិកាដែលយើងនឹងអនុវត្តជាដំណាក់កាល

- យន្តការថវិការរដបូកត្រូវចាប់ផ្តើមពី Sinking Fund ប៉ុន្តែនៅពេលដែលយើងមានចំណូលថវិកាបានមកពីប្រភពដទៃទៀតដូចជា ថវិកាបានពីការទូទាត់ផ្អែកតាមលទ្ធផល យើងនឹងអនុវត្តតាមជម្រើសយន្តការថវិកា Revolving Fund
- កិច្ចប្រជុំក្រុមការងាររដបូកកម្ពុជាលើកក្រោយៗ លេខាធិការដ្ឋានត្រូវអញ្ជើញក្រុមយេនឌ័រទាំងបួននាក់មកចូលរួមដើម្បីបង្ហាញពីវឌ្ឍនភាពការងារយេនឌ័រ
- លេខាធិការដ្ឋានត្រូវផ្ញើសេចក្តីព្រាងសន្ធានុក្រមរដបូក និងសេចក្តីសម្រេចCOP ជាថ្មីម្តងទៀតជូនលោក អ៊ុក វិបុល ដើម្បីជួយពិនិត្យកែសម្រួលលើឯកសារទាំង២នេះ
- លេខាធិការដ្ឋានត្រូវពិនិត្យកែសម្រួលអត្ថបទឃ្លាឃ្លោងឲ្យបានសមស្រប និងដាក់ជូនអ្នកពាក់ព័ន្ធពិនិត្យមុននឹងយកទៅបោះពុម្ព ឬ ផ្សព្វផ្សាយ
- លេខាធិការដ្ឋានត្រូវពិចារណាពីការរៀបចំ និងការគាំទ្រឲ្យមានក្រុមអ្នកកែសម្រួល
- ការសិក្សាស្តីពីការបែងចែកផលប្រយោជន៍រដបូកត្រូវធ្វើឲ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយសម្រាប់ការដាក់បញ្ចូលក្នុងយុទ្ធសាស្ត្ររដបូកជាតិ
- ក្រុមបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពត្រូវបន្តជំហាន(ទី៤ ទី៥ និងទី៦)ដែលនៅសល់ ដើម្បីបង្កើតប្រព័ន្ធព័ត៌មានប្រព័ន្ធធានាសុវត្ថិភាពរដបូកកម្ពុជាទៅតាមផែនការការងារឆ្នាំ២០១៥
- ត្រូវពិនិត្យ និងរៀបចំការគាំទ្រថវិកាដើម្បីទិញកាតទូរស័ព្ទជូនក្រុមបច្ចេកទេសតាមសំណូមពរ
- កិច្ចប្រជុំលើកទី៧ នឹងរៀបចំនៅខែមីនា ឆ្នាំ២០១៥ នៅក្រុងព្រះសីហនុ ដោយឡែកកាលបរិច្ឆេទ និងទីកន្លែងជាក់លាក់នៃកិច្ចប្រជុំ នឹងជូនដំណឹងនៅពេលក្រោយ។

ចុងបញ្ចប់ឯកឧត្តមបណ្ឌិតប្រធានអង្គប្រជុំ បានថ្លែងអំណរគុណចំពោះអ្នកចូលរួមទាំងអស់ ដែលបានចូលរួមមតិយោបល់ និងផ្តល់អនុសាសន៍ និងកោតសរសើរលេខាធិការដ្ឋានរដបូក ដែលបានរៀបចំ និងសម្របសម្រួលកិច្ចប្រជុំរហូតដល់ទីបញ្ចប់ និងសូមជូនពរឲ្យក្រុមការងាររដបូកសម្រេចការងារដោយជោគជ័យ។

អ្នកធ្វើកំណត់ហេតុ

ប្រធានអង្គប្រជុំ
បានឃើញ និងឯកភាព

លោក លន់ គឹមហ៊ី
អ្នកសម្របសម្រួលកម្មវិធីលេខាធិការដ្ឋានរដបូកកម្ពុជា